# មេរៀនទី ១៩៖ ពួកសាវកមានសេចក្តីជំនឿរឹងមាំ

## កិច្ចការ ៥៖១២-៤២

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/9jSlIu7EfcU

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/XCf1vsUk3bQ

**គោលបំណង៖** ក្លាហានក្នុងការដើរតាមព្រះ

**ខគម្ពីរចងចាំ៖ យ៉ូស្វេ ១៖៩** *"តើអញមិនបានបង្គាប់ឯងទេឬអី ដូច្នេះចូរឲ្យមានកំឡាំង និងចិត្តក្លាហានចុះ កុំឲ្យខ្លាចឡើយ ក៏កុំឲ្យស្រយុតចិត្តផង ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់គង់ជាមួយនៅកន្លែងណាដែលឯងទៅផង"។*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះអម្ចាស់ទ្រង់ស្ថិតស្ថេរ https://youtu.be/suW4J1Wbxa4

២. ក្នុងព្រះនាមព្រះយេស៊ូវ https://youtu.be/0b41QksexPE

៣. ខ្ញុំទុកចិត្តដល់ព្រះយេស៊ូវ https://youtu.be/Vq_yln2huAM

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«ទន្សាយ ឬ អណ្តើក»**

១. ជ្រើសរើសសិស្សម្នាក់ឱ្យធ្វើជា "អ្នកចាំទី" ហើយឱ្យកុមារផ្សេងទៀតឈរនៅជ្រុងម្ខាងទៀតក្នុងបន្ទប់។






២. "អ្នកចាំទី" អាចឈរបែរមុខរកជញ្ជាំង (ឲ្យឆ្ងាយ ពីក្មេងផ្សេងៗទៀត) ហើយនិយាយថា"ទន្សាយ" ឬ "អណ្តើក"

៣. ពេលដែល "អ្នកចាំទី" និយាយថា "ទន្សាយ" ក្មេងផ្សេងៗទៀតត្រូវដើរឲ្យលឿនទៅរកអ្នកចាំទី






៤.នៅពេលដែល "អ្នកចាំទី" និយាយថា "អណ្តើក" ក្មេងៗគ្រប់គ្នាត្រូវនៅស្ងៀម។ ប្រសិន បើ"អ្នកចាំទី"

៥.កុមារណាដែលបានទៅប៉ះ "អ្នកចាំទី" ដំបូងគេ នៅពេលដែលអ្នកចាំទីបែរមុខទៅរកជញ្ជាំង គឺជាអ្នកឈ្នះ ។

បែរក្រោយឃើញនរណាម្នាក់ផ្លាស់ទីពួកគេនឹង
ចាញ់ល្បែងនេះ

៦. សូមពន្យល់ដល់កុមារថា ពួកគេត្រូវតែក្លាហាន ដើម្បីធ្វើជាអ្នកដើរតាមព្រះដ៏រឹងមាំ ។

## ៤. ការណែនាំមេរៀន

តើប្អូនខ្លាចអ្វី?(ទុកឲ្យកុមារឆ្លើយ) នៅថ្ងៃនេះយើងនឹងរៀនអំពីពួកសាវ័ក ដែលបន្ទាប់ពីព្រះយេស៊ូវបានសុគត និងរស់ឡើងវិញ។ មនុស្សជាច្រើនចង់ដាក់ទោសពួកគេ ដោយសារតែពួកគេបានបានប្រាប់ដល់មនុស្សឯទៀតអំពីព្រះយេស៊ូវ។ ប្រសិនបើអ្នកជាសាវ័កម្នាក់ក្នុងចំណោមពួកគេទាំងនោះ តើអ្នកនឹងធ្វើដូចម្តេច? តើអ្នកនឹងបន្តប្រាប់អ្នកដទៃអំពីព្រះយេស៊ូវ ដោយភាពក្លាហានទៀតដែរឬទេ? ឬក៏អ្នកនឹងឈប់ធ្វើការនោះទៀតហើយទៅលាក់ខ្លួនវិញ? យើងនឹងរៀនជាមួយគ្នាពីពួកសាវ័ក ថាតើយើងត្រូវធ្វើដូចម្តេចដើម្បីបន្តដើរតាមព្រះដោយភាពក្លាហាន!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ ក្រុមជំនុំបានប្រឈមមុខនឹងការបៀតបៀន។ ទាំងជនជាតិរ៉ូម និងមេដឹកនាំសាសន៍យូដាបានបៀតបៀនអ្នកដើរតាមព្រះយេស៊ូវ ដើម្បីមិនឲ្យក្រុមជំនុំអាចដំណើរការបាន។ ប៉ុន្តែពួកសាវ័កបានផ្សាយដំណឹងល្អដោយភាពក្លាហាន ទោះបីជាពួកគេត្រូវប្រឈមនឹងការជាប់គុក ការធ្វើទារុណកម្ម និងការស្លាប់ក៏ដោយ។ ពួកគេក្លាហាន ដោយសារតែព្រះបានប្រទានកម្លាំង និងចិត្តក្លាហានដល់ពួកគេ។ មនុស្ស រាប់ពាន់នាក់បានជឿព្រះយេស៊ូវ។

ថ្ងៃមួយ ពេត្រុស និងអ្នកដើរតាមព្រះយេស៊ូវផ្សេងទៀតកំពុងតែប្រាប់មនុស្សទាំងអស់អំពីដំណឹងល្អរបស់ព្រះយេស៊ូវនៅឯព្រះវិហារ ។ មេដឹកនាំក្រុមជំនុំខ្លះខឹងនឹងពេត្រុស ហើយនឹងអ្នកដើរតាមឯទៀត។ ពួកគេមិនយល់ថា ព្រះយេស៊ូវជាព្រះរាជបុត្រារបស់ព្រះនោះទេ ហើយពួកគេកាន់តែមិនចង់ឱ្យពេត្រុស និងមិត្តភក្តិរបស់គាត់ប្រាប់មនុស្សអំពីព្រះយេស៊ូវនោះដែរ។ ដូច្នេះពួកគេបានចាប់ពេត្រុស និងមិត្តភក្តិរបស់គាត់ដាក់គុក។ នៅយប់នោះមាន ទេវតាបានមកបើកទ្វារគុក។ ទេវតាប្រាប់ពេត្រុស និងអ្នកដើរតាមផ្សេងទៀតឲ្យត្រឡប់ទៅព្រះវិហារ ហើយបន្តប្រាប់មនុស្សអំពីព្រះយេស៊ូវទៀត។ ព្រះគម្ពីរប្រាប់យើងថា ពេត្រុស និងមិត្តភក្តិរបស់គាត់បានធ្វើដូចអ្វី ដែលទេវតាបានប្រាប់ពួកគាត់ឱ្យធ្វើ។ ពួកគាត់ក៏ត្រឡប់ទៅព្រះវិហារវិញ ហើយប្រាប់ប្រជាជនអំពី ព្រះយេស៊ូវ។ មនុស្សដែលបានចាប់ពេត្រុស និងមិត្តភក្តិរបស់គាត់ដាក់គុកមានការភ្ញាក់ផ្អើលនៅពេលដែលពួកគេបានទៅដល់ព្រះវិហារ ហើយបានឃើញពេត្រុស និងមិត្តរបស់គាត់កំពុងអធិប្បាយនៅទីនោះទៀត។ ពួកឆ្មាំគុកបាននាំពេត្រុស និងមិត្តភក្តិរបស់គាត់ទៅនិយាយជាមួយពួកមេដឹកនាំរបស់ពួកគេ។ ព្រះគម្ពីរ **កិច្ចការ ៥៖២៩** «តែពេត្រុស និងពួកសាវ័កឯទៀតឆ្លើយឡើងថាត្រូវតែស្តាប់បង្គាប់របស់ព្រះជាជាងមនុស្ស »។ បន្ទាប់មក ពេត្រុស និងមិត្តភក្តិរបស់គាត់បានប្រាប់ ពួកមេដឹកនាំទាំងអស់នោះអំពីព្រះយេស៊ូវ។ ពេត្រុស និងមិត្តភក្តិរបស់គាត់ មានភាពក្លាហាន! ទោះបីជាមានរឿងអ្វីក៏ដោយ ពួកគេនៅតែដើរតាមព្រះយេស៊ូវ!

ការដើរតាមព្រះដោយភាពក្លាហានគឺមិនងាយស្រួលនោះទេ។ ប៉ុន្តែយើងអាចធ្វើតាមគំរូរបស់លោកពេ-ត្រុសបាន ។ ទោះជាក្នុងពេលដែលមានរឿងអាក្រក់កើតឡើងក៏ដោយ ពេត្រុសនៅតែស្តាប់បង្គាប់ព្រះ ហើយបន្តប្រាប់មនុស្សអំពីព្រះយេស៊ូវ។ គាត់ដឹងថាមនុស្សត្រូវដឹងអំពីព្រះយេស៊ូវ។ ដំណឹងល្អអំពី ព្រះយេ-

ស៊ូវគឺជាដំណឹងដ៏ល្អបំផុតដែលមិនធ្លាប់មាន។ យើងក៏អាចដើរតាមព្រះដោយក្លាហាន ហើយប្រាប់អ្នកឯទៀតអំពីព្រះយេស៊ូវបានដែរ។ ប៉ុន្តែវាពិបាកណាស់ក្នុងការដែលដើរតាមព្រះនិងប្រាប់អ្នកដទៃអំពីទ្រង់ដោយភាពក្លាហាននោះ។ មិត្តភក្តិរបស់យើងប្រហែលជាមិនស្តាប់យើងទេ ឬពួកគេប្រហែលជាសើចចំអកឲ្យយើងទៀតផង។ ប៉ុន្តែយើងធ្វើឲ្យព្រះសប្បាយព្រះទ័យ ហើយបង្ហាញថាទ្រង់សំខាន់ចំពោះយើងពេលយើងធ្វើតាមទ្រង់ដោយក្លាហាន ទោះជាមានការលំបាកយ៉ាងណាក៏ដោយ។ យើងអាចដឹងថា ទ្រង់នឹងនៅជាមួយយើង ហើយផ្តល់ឱ្យយើងនូវកម្លាំង និងភាពក្លាហាន ដែលយើងត្រូវការ។

## ៦. សំនួរពិភាក្សា

១. តើមានអ្វីកើតឡើងបន្ទាប់ពីព្រះយេស៊ូវបានសុគត ហើយរស់ឡើងវិញ? *(ក្រុមជំនុំប្រឈមនឹងការបៀតបៀន)*

២. តើនរណាជាអ្នកបៀតបៀនក្រុមជំនុំ? *(ជនជាតិរ៉ូម និងមេដឹកនាំសាសន៍យូដា)*

៣. ហេតុអ្វីបានជាសាវ័កជ្រើសរើសនៅតែជ្រើសរើសយកការប្រាប់អ្នកដទៃពីព្រះយេស៊ូវ បើទោះជា ពេលពួកគេត្រូវគេបៀតបៀនក៏ដោយនោះ? *( ពួកគេបានដឹងថាមនុស្សត្រូវការដឹងអំពីព្រះយេស៊ូវ )*

៤. តើអ្នកអាចធ្វើអ្វីដើម្បីធ្វើជាអ្នកដើរតាមព្រះដ៏ក្លាហាន? *(ក្លាហានហ៊ានប្រាប់អ្នកដទៃអំពីព្រះយេស៊ូវ)*

៥. តើអ្នកណានឹងជួយយើងឲ្យដើរតាមព្រះដោយក្លាហាន? *(ព្រះយេស៊ូវ)*

## ៧. ល្បែងកំសាន្ត «ចូរក្លាហាន»




១.យើងបែងចែកកុមារជា២ក្រុម ត្រូវជ្រើសរើសមេក្រុមម្នាក់សម្រាប់ក្រុមនីមួយៗ

២.ពន្យល់កាយវិកាយះ

- សត្វតោគឺយើងយកដៃទាំង២ធ្វើក្រញាំដាក់ក្បែរត្រចៀកទាំងសងខាង ហើយគ្រហឹម។
- ដានីញ៉ែល គឺអធិស្ឋានដោយលើកដៃសំពះ។

៣.ឲ្យកុមារឈរជាជួរដោយបែរខ្នងដាក់គ្នា កុមារតាមក្រុមនីមួយៗត្រូវពិភាក្សាគ្នាដើម្បីជ្រើសរើសយកកាយវិការមួយសម្រាប់ក្រុមរបស់ខ្លួន។

៤.ពេលគ្រូស្រែក ១ ២ ៣ កុមារទាំងពីរក្រុមត្រូវបែរមុខដាក់គ្នាដោយធ្វើកាយវិការ ដែលក្រុមរបស់ខ្លួនបានជ្រើសរើស។

៥.ក្រុមណាដែលធ្វើជាដានីយ៉ែល ក្រុមនោះជាអ្នកឈ្នះ បើក្រុមទាំង២ចេញកាយវិការដូចគ្នា ត្រូវឲ្យក្រុមទាំងពីរបន្តលេងទៀតរហូតដល់មានក្រុមដែលឈ្នះ(គ្រូមិនត្រូវប្រាប់ពីលក្ខខណ្ឌនៃការឈ្នះល្បែងនេះមុនជាដាច់ខាត)។

## ៨. ខគម្ពីរចងចាំ

**យ៉ូស្វេ ១៖៩** *"តើអញមិនបានបង្គាប់ឯងទេឬអី ដូច្នេះចូរឲ្យមានកំឡាំង និងចិត្តក្លាហានចុះ កុំឲ្យខ្លាចឡើយ ក៏កុំឲ្យស្រយុតចិត្តផង ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯងទ្រង់គង់ជាមួយនៅកន្លែងណា ដែលឯងទៅផង។"*

## ៩. ហាត្ថកម្ម

សូមផាត់ពណ៌គំនូសនៅទំព័រខាងក្រោម ហើយសរសេរខគម្ពីរចងចាំ (សូមបោះពុម្ពទំព័រខាងក្រោម)

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

នៅពេលយើងរីកចម្រើនក្នុងទំនាក់ទំនងរបស់យើងជាមួយព្រះយេស៊ូវ ព្រះវិញ្ញាណបរិសុទ្ធដឹកនាំ និងបំផុសគំនិតយើង ។ សូមដកដង្ហើមវែងៗ។ អ្នកនៅមានជីវិតរស់អាចដកដង្ហើមបានធ្វើចលនាបាន ហើយជីវិតអ្នកមានន័យដោយសារអ្នកមានវិញ្ញាណ។ ដែលវិញ្ញាណនេះហើយ ជាអ្នកបំបែកអ្នកពីសេចក្ដីស្លាប់។ មិនត្រឹមតែប៉ុណ្ណោះ ព្រះទ្រង់បានប្រទានព្រះវិញ្ញាណរបស់ទ្រង់មករស់នៅក្នុងអ្នក ធ្វើឱ្យអ្នកនៅមានជីវិតរស់នៅ ហើយរស់នៅសម្រាប់ព្រះអង្គ។ សូមកុំខ្ជះខ្ជាយជីវិតរបស់អ្នកនៅថ្ងៃនេះឡើយ។ ចូររស់នៅក្នុងព្រះគ្រីស្ទ ដែលមានព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងអ្នក។



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________

______________________________________________

______________________________________________